New South Wales Government
Attorney General's Department
lawaccess

Khmer

# ត្រូវការជំនួយលើ**បញ្ហាផ្លូវច្បាប់**ឬទេ?

**LawAccess NSW** គឺជាសេវាទូរស័ព្ទឥតគិតថ្លៃរបស់រដ្ឋាភិបាល ដែលផ្តល់ព័ត៌មាននិងឱវាទផ្លូវច្បាប់ ហើយនិងការបញ្ជូនសំរាប់អ្នកដែលមានបញ្ហាផ្លូវច្បាប់នៅក្នុងរដ្ឋ NSW ។

## តើយើងខ្ញុំអាចជួយលោកអ្នកតាមវិធីណា?

បើលោកអ្នកត្រូវឡើងតុលាការ មានបញ្ហាផ្លូវច្បាប់ ឬមានសំណួរអំពីច្បាប់ យើងខ្ញុំអាចជួយលោកអ្នកក្នុងការទទួលជំនួយដែលលោកអ្នកត្រូវការ។

យើងខ្ញុំមានភ្នាក់ងារសេវាអតិថិជនដែលអាច៖

- ផ្តល់ជូនលោកអ្នកនូវព័ត៌មានដើម្បីជួយលោកអ្នកលើបញ្ហាផ្លូវច្បាប់។
- រៀបចំអោយភ្នាក់ងារច្បាប់ម្នាក់របស់យើងខ្ញុំផ្តល់ជូនលោកអ្នកនូវឱវាទផ្លូវច្បាប់តាមទូរស័ព្ទ បើសេចក្តីត្រូវការរបស់លោកអ្នកមានភាពសមស្របនឹងគោលការណ៍យើងខ្ញុំអំពីការទទួលឱវាទផ្លូវច្បាប់។
- បញ្ជូនលោកអ្នកទៅកាន់សេវាច្បាប់ឬសេវាពាក់ព័ន្ធមួយទៀត ដែលនឹងមានសមត្ថភាពប្រសើរបំផុតដើម្បីជួយលោកអ្នក។
- ផ្ញើជូនលោកអ្នកនូវព័ត៌មានដែលអាចជួយលោកអ្នកលើបញ្ហាផ្លូវច្បាប់។

LawAccess NSW ត្រូវបានបង្កើតឡើងដើម្បីជួយអ្នកដែលមានការលំបាកក្នុងការទទួលសេវាផ្លូវច្បាប់។ជាពិសេស យើងខ្ញុំជួយអតិថិជនដែល៖

- រស់នៅក្នុងតំបន់ជនបទនៃរដ្ឋ NSW
- ជាជនជាតិដើម Aboriginal ឬ Torres Strait Islander
- មានពិការភាព
- មកពីសាវតារដែលមានវប្បធម៌និងភាសាផ្សេងៗគ្នា
- អាចមានគ្រោះថ្នាក់

យើងខ្ញុំទទួលស្គាល់ថា ប្រជាពលរដ្ឋមានការលំបាកក្នុងការទទួលសេវាផ្លូវច្បាប់សមស្រប ដោយសារតែមូលហេតុផ្សេងទៀតជាច្រើន។ ភ្នាក់ងារសេវាអតិថិជនរបស់យើងខ្ញុំទទួលការបណ្តុះបណ្តាលដើម្បីជួយលោកអ្នកក្នុងការស្វែងរកជំនួយដែលលោកអ្នកត្រូវការ។

## តើបញ្ហាផ្លូវច្បាប់ប្រភេទណាដែលយើងខ្ញុំអាចជួយលោកអ្នកបាន?

យើងខ្ញុំអាចជួយលោកអ្នកលើបញ្ហាផ្លូវច្បាប់មួយចំនួនដោយមានរួមទាំង៖

- បញ្ហាប្រាក់ជំពាក់និងឥណទាន
- ច្បាប់គ្រួសារនិងចំណងមេត្រីភាពដូចប្តីប្រពន្ធ
- ទំនាស់ជាមួយអ្នកជិតខាង
- បណ្តាំកេរ្តិ៍មរតកនិងគេហដ្ឋានដីធ្លី
- បទល្មើសចរាចរណ៍
- ច្បាប់ប្រកបការងារ
- ច្បាប់ព្រហ្មទណ្ឌ
- ដីកាហាមឃាត់អំពើហិង្សា (Apprehended Violence Orders - AVOs)
- ច្បាប់អ្នកប្រើប្រាស់
- គ្រោះថ្នាក់រថយន្ត
- បណ្តឹងអំពីមេធាវី

## តើលោកអ្នកអាចទាក់ទងយើងខ្ញុំតាមរបៀបណា?

### ទូរស័ព្ទ

លោកអ្នកអាចទូរស័ព្ទមកយើងខ្ញុំតាមលេខ **1300 888 529** ពីម៉ោង 9ព្រឹក ដល់ម៉ោង 5ល្ងាច ថ្ងៃច័ន្ទដល់ថ្ងៃសុក្រ (លើកលែងតែថ្ងៃឈប់សំរាកសាធារណៈ)។

បើលោកអ្នកមានពិការភាពក្នុងការស្តាប់ឬនិយាយ លោកអ្នកអាចទូរស័ព្ទមកយើងខ្ញុំតាមលេខ **1300 889 529** ពីម៉ោង 9ព្រឹក ដល់ម៉ោង 5ល្ងាច ថ្ងៃច័ន្ទដល់ថ្ងៃសុក្រ (លើកលែងតែថ្ងៃឈប់សំរាកសាធារណៈ)។

## សេវាបកប្រែភាសា (TIS)

លោកអ្នកអាចទាក់ទងយើងខ្ញុំតាមរយៈសេវាបកប្រែភាសា (TIS) តាមទូរស័ព្ទលេខ **131 450** ។ TIS នឹងរៀបចំអោយមានអ្នកបកប្រែភាសារបស់លោកអ្នកតាមទូរស័ព្ទនៅពេលដែលលោកអ្នកទាក់ទងយើងខ្ញុំ។
TIS គឺជាសេវាឥតគិតថ្លៃនិងលាក់ការសម្ងាត់។

## វិបសៃ LawAccess

វិបសៃ **www.lawaccess.nsw.gov.au** យើងខ្ញុំគឺជាកន្លែងចាប់ផ្តើមដ៏សំខាន់ដើម្បីស្វែងរកព័ត៌មានអំពីបញ្ហាផ្លូវច្បាប់ ឬសំណួរអំពីច្បាប់។

ដោយប្រើវិបសៃយើងខ្ញុំ លោកអ្នកនឹងអាច៖

- បើកមើលព័ត៌មានផ្លូវច្បាប់ដែលងាយអានជាង 2000 ដូចជាប័ណ្ណព័ត៌មាន ក្រដាសបំពេញ និងឯកសារបោះផ្សាយទាំងឡាយ។
- រកឃើញដោយងាយស្រួលនូវព័ត៌មាននៅក្នុងផ្នែកច្បាប់ទូទៅនានា ដូចជាបញ្ហាប្រាក់ជំពាក់ច្បាប់គ្រួសារ និងអ្នកជិតខាង។
- បើកមើលព័ត៌មាននិងឯកសារបោះផ្សាយទាំងឡាយដែលផលិតដោយសេវាផ្លូវច្បាប់របស់រដ្ឋាភិបាល និងក្រៅរដ្ឋាភិបាលមួយចំនួនផ្សេងៗគ្នា ដូចជា Legal Aid NSW, Community Legal Centres និងតុលាការក្នុងតំបន់ឬតុលាការគ្រួសារ។

វិបសៃយើងខ្ញុំផ្តល់ភាពងាយស្រួលក្នុងការស្វែងរក ហើយលោកអ្នកអាចបើកមើលគ្រប់ពេលទាំងអស់។

## សេវាបញ្ជូនទៅមេធាវី

តើលោកអ្នកត្រូវការរកមេធាវីផ្ទាល់ខ្លួនឬទេ? បើលោកអ្នកត្រូវការជំនួយពីមេធាវីផ្ទាល់ខ្លួន យើងខ្ញុំអាចធ្វើការរួមគ្នាជាមួយនឹង Law Society of NSW ដើម្បីរកមើលឈ្មោះមេធាវីឯកជនបីនាក់នៅក្នុងទីកន្លែងឬផ្នែកណាមួយនៃច្បាប់ ដើម្បីផ្ញើជូនលោកអ្នកតាមប្រៃសណីយ៍ ទូរសារ ឬអ៊ីមែល។

## តើខ្ញុំអាចទទួលឱវាទផ្លូវច្បាប់ពី LawAccess NSW ឬទេ?

យើងខ្ញុំមានភ្នាក់ងារច្បាប់ដែលអាចផ្តល់ឱវាទផ្លូវច្បាប់តាមទូរស័ព្ទ។ យ៉ាងណាមិញ យើងខ្ញុំមិនអាចផ្តល់ឱវាទផ្លូវច្បាប់ជូនជនរាល់រូបបានទេ។ ការសាកសួរផ្លូវច្បាប់ត្រូវតែមានភាពសមស្របនឹងគោលការណ៍យើងខ្ញុំអំពីសិទ្ធិទទួលឱវាទផ្លូវច្បាប់ ហើយត្រូវតែសមរម្យនឹងពិភាក្សាតាមទូរស័ព្ទ។

## តើខ្ញុំអាចទទួល Legal Aid (ជំនួយផ្លូវច្បាប់) ឬទេ?

ថាតើលោកអ្នកអាចទទួល Legal Aid ដែរឬទេនោះ គឺអាស្រ័យលើប្រភេទនៃបញ្ហាដែលលោកអ្នកមាន និងប្រាក់ចំណូលរបស់លោកអ្នក។ បើលោកអ្នកមិនដឹងច្បាស់ថាតើលោកអ្នកនឹងទទួល Legal Aid ឬទេនោះ ភ្នាក់ងារសេវាអតិថិជនរបស់យើងខ្ញុំអាចជួយលោកអ្នកដើម្បីរកមើលថាតើលោកអ្នកអាចទទួល Legal Aid ឬទេ និងជួយលោកអ្នកក្នុងការសរសេរបំពេញពាក្យសុំ Legal Aid ។

## ហេតុអ្វីបានជាយើងខ្ញុំបញ្ជូនទៅកាន់សេវាផ្សេងទៀត?

ក្រោយពីស្តាប់បញ្ហាផ្លូវច្បាប់របស់លោកអ្នកហើយ ភ្នាក់ងារសេវាអតិថិជនរបស់យើងខ្ញុំអាចរកមើលដឹងថាសេវាឯកទេសមួយផ្សេងទៀតប្រហែលជាផ្តល់ជំនួយជូនលោកអ្នកប្រសើរជាងយើងខ្ញុំ។ ជួនកាលបញ្ហាផ្លូវច្បាប់របស់លោកអ្នកអាចទទួលការដោះស្រាយរឹតតែសមរម្យឡើងតាមរយៈការទៅជួបទល់មុខគ្នាជាមួយអ្នកណាម្នាក់។ ភ្នាក់ងារសេវាអតិថិជនរបស់យើងខ្ញុំនឹងធ្វើប្រាកដថា លោកអ្នកមានទំនាក់ទំនងជាមួយសេវាសមរម្យបំផុត។

LawAccess NSW គឺជាការផ្តួចផ្តើមរបស់ Attorney General's Department of NSW, Legal Aid NSW, Law Society of NSW និង NSW Bar Association។

© រដ្ឋ New South Wales តាមរយៈ LawAccess NSW, Attorney General's Department.
លោកអ្នកអាចប្រើប្រាស់ឯកសារនេះសំរាប់គោលបំណងណាមួយក្រៅតែអំពីការរកប្រាក់ចំណេញ។
មិថុនា 2008 ISBN 978-1-921301-74-2.

ដើម្បីទទួលព័ត៌មានបន្ថែមអំពីទំរង់ផ្សេងទៀត សូមទាក់ទង LawAccess NSW តាមទូរស័ព្ទលេខ 1300 888 529 (TTY 1300 889 529)។